សំណួរដែល
គេតែងតែសួរ
ជាញឹកញាប់

# ប្រព័ន្ធស្ទង់មើលសាលានៅរដ្ឋផិនសល់វេញ៉ា (PSSA)
# ការស្ទង់មើលផ្នែកគណិតសាស្ត្រនិងអាន
# ថ្នាក់ទី៣-ទី៨ និង ទី១១ – មិនា ២០០៩
# ពត៌មានសម្រាប់មាតាបិតាឬអាណាព្យាបាល

**តើសាលាណាខ្លះដែលចូលរួម?**
សាលារបស់ក្រសួងអប់រំទាំងអស់ចូលរួមក្នុងការស្ទង់មើលគណិតសាស្ត្រនិងអាន។ សាលាដែលមិនមែនជាសាលាសាធារណៈនិង សាលាឯកជនក៏អាចចូលរួមតាមការស្ម័គ្រចិត្ត។

**តើសិស្សណាខ្លះដែលត្រូវមានការស្ទង់មើល?**
សិស្សទាំងអស់ដែលរៀនថ្នាក់ទី៣ - ទី៨ និងទី១១ ត្រូវតំរូវឲ្យមានការស្ទង់មើល (លើកលែងតែសិស្សមួយចំនួនតូចដែលត្រូវតាមលក្ខណៈវិនិច្ឆ័យចំៗណាមួយ)។

**តើការស្ទង់មើលធ្វើឡើងនៅពេលណា?**
ការស្ទង់មើលណាត់ពេលដោយក្រសួងអប់រំ រយៈពេលធ្វើតេះ ចាប់ពីខែមិនា ទី១៦ ដល់ ខែមិនា ទី២៧ ឆ្នាំ២០០៩ ។

**តើការស្ទង់មើលនេះស៊ីពេលប៉ុន្មាន?**
ការស្ទង់មើលគណិតសាស្រនិងអាន្ត ស៊ីពេលប្រហែលពីរទៅប្រាំមួយទៅប្រាំពីរម៉ោង ទើបធ្វើចប់។ ក្រសួងអប់រំរបស់លោកអ្នកនឹងជូនដំណឹងដល់លោកអ្នកអំពីពេលវេលាស្ទង់មើល។

**តើការស្ទង់មើលមានអ្វីខ្លះ?**
សិស្សម្នាក់ៗបំពេញប្រការនៃការស្ទង់មើលបីជំពូក សម្រាប់គណិតសាស្ត្រនិងអាន។ ជំពូកខ្លះដូចៗគ្នា សម្រាប់សិស្សទាំង អស់ ហើយជំពូកខ្លះទៀតនឹងមានក្រុមប្រការខុសៗគ្នា។

**តើការស្ទង់មើលមានសំណួរប្រភេទណាខ្លះ?**
សិស្សឆ្លើយសំណួរពីរប្រភេទៈ រើសយកចំឡើយមួយពីសំណួរ ជាច្រើន និងឆ្លើយតាមការសរសេរ។ ការរើសយកចំឡើយមួយ ពីសំណួរជាច្រើន គឺរើសយកចំឡើយមួយដែលត្រូវ ចេញពីសំ ណួរបួនដែលដាក់ឲ្យ ហើយចំឡើយតាមការសរសេរ តំរូវឲ្យ សិស្សសរសេរនូវចំឡើយរបស់ពួកគេ។

**តើសិស្សទទួលពិន្ទុរបៀបណា សរាប់ចំឡើយតាមការសរសេរ?**
ចំឡើយតាមការសរសេរសម្រាប់គណិតសាស្ត្រនិងអាននឹងឲ្យពិន្ទុដោយអ្នកឲ្យពិន្ទុដែលមានការហ្វឹកហ្វឺនតាមប្រព័ន្ធឲ្យពិន្ទុដែល មានការសំរេចជាមុន។ ក្នុងការអាននិងគណិតសាស្ត្រ ការឲ្យពិន្ទុ យោងទៅតាមអ្វីៗដែលមានតែប៉ុណ្ណោះ។ ការប្រកបនិងវិធីប្រើ វណ្ណយុត្ត គឺមិនរាប់បញ្ចូលក្នុងការឲ្យពិន្ទុទេ។

**តើអ្នកណាជាអ្នកសំរេចថាត្រូវធ្វើអ្វីខ្លះក្នុងការស្ទង់មើល?**
ក្រុមអ្នកវិជ្ជាកោសល្យគ្រប់ជាន់ថ្នាក់ទាំងអស់នៅរដ្ឋផិនសល់វេញ៉ា ជ្រើសរើសមុខវិជ្ជាដែលយកមកស្ទង់មើល។ ក្រុមនេះមានទាំង គ្រូបង្រៀន អ្នកមើលខុសត្រូវ នាយកនៃកម្មវិធី និងអ្នកឯកទេស នៅមហាវិទ្យាល័យ។ ហើយក្រុមនេះ ពិនត្យមើល ពិនិត្យផ្ទៀងផ្ទាត់ ហើយយល់ព្រមនូវប្រការដែលបានសរសេរដើម្បីឲ្យស្រប តាមមូលដ្ឋានស្ទង់មើលរបស់រដ្ឋផិនសល់វេញ៉ា។

**តើអ្នកណាជាអ្នកធ្វើការស្ទង់មើល?**
សាលានិមួយៗរើសអ្នកដែលធ្វើការស្ទង់មើល។ ភាគច្រើន អ្នកទាំងនេះគឺជានិស្សិតដែលហាត់រៀនឲ្យក្លាយទៅជាគ្រូបង្រៀន ដែលតែងតែមានជំនួយពីចាងហ្វាងសាលាឬអ្នកឲ្យឱវាទនៅសា លា។

**តើការស្ទង់មើលលើការអានមានអ្វីខ្លះ?**
ការស្ទង់មើលលើការអាន សំដៅទៅលើការរាយការណ៍ធំពីរ។ សិស្សអានរឿងប្រឌិតនិងមិនប្រឌិត ហើយឆ្លើយសំណួរអំពីរឿង ទាំងនេះ។ ដោយឆ្លើយនឹងរឿងទាំងនេះ សិស្សបង្ហាញនូងការយល់ដឹងនិងការប៉ិនប្រសប់ក្នុងការអាន ហើយធ្វើពិភាគនិងធ្វើការបកប្រែរឿងប្រឌិតនិងមិនប្រឌិត។

**តើការស្ទង់មើលលើគណិតសាស្ត្រមានអ្វីខ្លះ?**
ការស្ទង់មើលលើគណិតសាស្ត្រ សំដៅទៅលើការរាយការណ៏ធំ ប្រាំ។ ជំពូកនិមួយៗគឺខុសៗគ្នា ទៅតាមកំរិតថ្នាក់។ ផ្នែករាយ ការណ៏ប្រភេទ A *មានលេខនិងធ្វើលេខ* សិស្សឆ្លើយសំណួរ តាមជំពូកពិសេសៗដែលមិនអនុញ្ញាតឲ្យប្រើម៉ាស៊ីនគិតលេខ សំណួរក្នុងការស្ទង់មើលតម្រូវឲ្យសិស្សបង្ហាញនូវការគិតលេខទាំងអស់របស់ពួកគេ (របៀបគិតលេខ គូរក្រាហ្វិក គូររូប ។ល។ ហើយពន្យល់តាមការសរសេរថាតើពួកគេដោះស្រាយចំណោទដោយរបៀបណា។

**តើលទ្ធផលត្រូវរាយការណ៏របៀបណា?**
សេចក្តីរាយការណ៏សម្រាប់ការអាននិងគណិតសាស្ត្រត្រូវបញ្ជូនទៅក្រសួងអប់រំដើម្បីចែកចាយទៅមាតាបិតា គ្រូ និងអ្នកឲ្យឱវាទ នៅសាលានិង/ឬចាងហ្វាងសាលា។ រដ្ឋនឹងមិនទទួលនូវសេចក្តី រាយការណ៏ណាដែលមានឈ្មោះសិស្សទេ។
លទ្ធផលត្រូវបានរាយការណ៏ដោយសាលា សម្រាប់គោលបំណងនៃកម្មវិធីនិងគំរោងការណ៏។ ក្រសួងអប់រំបោះពុម្ពលទ្ធផលនៃការ ធ្វើតេះ PSSA សម្រាប់សាលានិមួយៗ។ រដ្ឋក៏បញ្ចេញទិន្នន័យនៃការស្ទង់មើលរបស់សាលានិមួយៗដែរ។

**តើមាតាបិតាអាចមើលការស្ទង់មើលបានទេ?**
មាតាបិតាឬអាណាព្យាបាលអាចពិនិត្យមើលការស្ទង់មើលទាំងនេះដោយធ្វើការរៀបចំជាមួយអ្នកចាត់ចែងខាងការស្ទង់មើលនៅសាលាពេលណាការស្ទង់មើលមកដល់សាលា។ ការស្ទង់មើលឬកំណត់សំគាល់អំពីប្រការនាៗមិនអាចយកចេញទៅក្រៅសាលាបានទេ ហើយត្រូវមានការចុះហត្ថលេខាពីការរក្សាទុកជាសម្ងាត់។ ក្រោយពីបានពិនិត្យមើលការស្ទង់មើលរួចហើយ បើមាតាបិតាមិនចង់ឲ្យកូនចូលរួមក្នុងការស្ទង់មើលលើការអាននិងគណិតសាស្ត្រ ដោយមានការប៉ះពាល់ដល់ជំនឿសាសនារបស់ពួកគេ ពួកគេអាចសរសេរសំបុត្រទៅអ្នកចាត់ចែងក្រសួងអប់រំ មុនពេលចាប់ផ្តើម ការស្ទង់មើលដើម្បីទទួលការអត់អោនអោយកូនពីការធ្វើការ ស្ទង់មើល។